ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ២ | មេសា - មិថុនា ឆ្នាំ២០០៩ | តម្លៃ ១.៥០០៛

# សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៩ "ប្រទេសកម្ពុជា និង វិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព"*



ភ្ញៀវទេសចរចូលមកប្រទេសកម្ពុជា តាមច្រកព្រំដែនប៉ោយប៉ែត

សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៣ ដែលផ្ដោតលើប្រធានបទ "ប្រទេសកម្ពុជា និងវិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព" បានប្រារព្ធធ្វើនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១២ មីនា ២០០៩ ក្រោមកិច្ចសហការជាដៃគូរវាង វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal ។ ក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ប្រាប់ភ្ញៀវកិត្តិយសទាំង ៣៥០នាក់ថា "នេះជាព្រឹត្តិការណ៍ដ៏វិសេសមួយនៅប្រទេសកម្ពុជា ដែលជារៀងរាល់ឆ្នាំសន្និសីទនេះបានអញ្ជើញថ្នាក់ដឹកនាំមកពីខាង រដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ សង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ មកជួបប្រជុំគ្នា ដើម្បីពិចារណាលើសមិទ្ធផល និងអនាគតរបស់ប្រទេសកម្ពុជា ។ កាលបរិច្ឆេទ និងប្រធានបទសន្និសីទចក្ខុវិស័យនាឆ្នាំនេះ មានសារៈសំខាន់ជាពិសេស ពីព្រោះយើងកំពុងទទួលរងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងតំបន់ និងក្នុងពិភពលោក និងកំពុងប្រឹងប្រែងដោះស្រាយវិបត្តិទាំងនេះ ។"

សន្និសីទឆ្នាំ២០០៩ រួមមានវគ្គមួយចំនួនស្ដីពី វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ដល់តំបន់យើង និងប្រទេសកម្ពុជា, ការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជា - ការកសាងកំលាំងពលកម្មមានជំនាញ, ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ - ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំនើនទៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ, អាទិភាពសំរាប់គោលនយោបាយ និងការធ្វើសកម្មភាពដោយរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ស្ថាប័នខាងស្រាវជ្រាវ និងគោលនយោបាយ ។

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ក្នុងលេខពិសេសនេះ មានចុះផ្សាយអត្ថបទនានាស្ដីពីបទបង្ហាញ និងការពិភាក្សាទាំងឡាយ នៅក្នុងសន្និសីទ ។ វិទ្យាស្ថានក៏មានចេញផ្សាយ អត្ថបទសង្ខេបចក្ខុវិស័យប្រទេសកម្ពុជា មួយឈុត ជាភាសាខ្មែរ និងអង់គ្លេសផងដែរ ។ ម្យ៉ាងទៀត កម្មវិធីទាំងមូល បទបង្ហាញនានា និងឯកសារជាប់ទាក់ទងនឹងសន្និសីទទាំងអស់ មានចុះនៅក្នុងវេបសាយ របស់ CDRI ៕

## មាតិកា

ប្រទេសកម្ពុជា និងវិបត្តិសាកលៈ សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ .......... ២
វិបត្តិសាកល — ផលប៉ះពាល់ ចក្ខុវិស័យ... សំរាប់កម្ពុជា.......... ៤
វិបត្តិហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ក្នុងតំបន់.......... ៧
ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល លើផ្នែកវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា.......... ១១
ផលប៉ះពាល់ជាសក្ដានុពលនៃវិបត្តិហិរញ្ញវត្ថុទៅលើគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះនៅកម្ពុជា.......... ១៣
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — កសិកម្ម.......... ១៦
វិបត្តិអាហារ និងហិរញ្ញវត្ថុ — ផលប៉ះពាល់លើវិស័យកសិកម្ម.......... ១៩
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ទេសចរណ៍.......... ២៣
ការគ្រប់គ្រងវិបត្តិសាកល — ទេសចរណ៍នៅប្រទេសកម្ពុជា និងក្នុងតំបន់.......... ២៦
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ហេដ្ឋារចនាសម្ព័ន្ធ.......... ២៩
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — អចលនទ្រព្យ.......... ៣៣
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស.......... ៣៦
— ស្ថានភាពក្នុងប្រទេស.......... ៣៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI.......... ៤៤

* Larry Strange នាយកប្រតិបត្តិ CDRI ណែនាំបង្ហាញពីទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា លេខពិសេសនេះដែលផ្ដោតលើសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។

# ប្រទេសកម្ពុជា និងវិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព — សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩*

សន្និសីទចក្ខុវិស័យនៅឆ្នាំនេះ បានរៀបចំឡើងទាន់ពេលវេលា ហើយប្រធានបទដែលលើកឡើងនៅពេលនេះ មានសារៈសំខាន់ និងចំពេលវេលាដែលយើងទាំងអស់គ្នាកំពុងជួបនឹងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរិះរកវិធីសាស្ត្រ ដើម្បីឆ្លើយតបឱ្យបានស័ក្តិសម និងមានប្រសិទ្ធភាព ។ វិបត្តិនេះ មិនមែនកើតចេញពីកម្ពុជាទេ ។ វាកើតឡើងដោយកត្តាខាងក្រៅដែលហួសពីកំលាំងគ្រប់គ្រងរបស់កម្ពុជា ប៉ុន្តែជះឥទ្ធិពលយ៉ាងខ្លាំងមកលើយើងទាំងអស់គ្នា ។

## សមិទ្ធិផលក្នុងពេលកន្លងមកៈ កំណើន និង ការកាត់បន្ថយភាពក្រីក្រ

កម្ពុជាមានភ័ព្វសំណាង ដោយត្រូវប្រឈមមុខនឹងវិបត្តិ នៅចំពេលដែលសេដ្ឋកិច្ចរបស់ខ្លួនកំពុងមានសន្ទុះខ្លាំងនៅឡើយ ដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរក្នុងពេញមួយទសវត្សរ៍កន្លងមក ។ការសិក្សាមួយរបស់ធនាគារពិភពលោកនាពេលថ្មីៗនេះ បានដាក់បញ្ចូលកម្ពុជាក្នុងចំណោម ១០ប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេ គិតពីឆ្នាំ១៩៩៨ ដល់ ២០០៧ ដោយកម្ពុជាមានអត្រាកំណើនជាមធ្យមជាលេខពីរខ្ទង់ ក្នុងមួយទសវត្សរ៍កន្លងមក ។ ទន្ទឹមគ្នានេះ កម្ពុជាបានកាត់បន្ថយយ៉ាងច្រើននូវភាពក្រីក្រពី ៤៥% នៅឆ្នាំ ១៩៩៤ មកនៅត្រឹម ៣០% នៅឆ្នាំ២០០៨ ។

ជោគជ័យល្អវិសេសក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនេះ អាចសម្រេចបានតាមរយៈ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ព្រមទាំងសន្ទុះលូតលាស់របស់វិស័យឯកជន និងការខិតខំប្រឹងប្រែង និងផលិតភាពរបស់ប្រជាជនកម្ពុជា ។ ប្រទេសកម្ពុជា បានជឿនលឿនទៅមុខយ៉ាងច្រើន ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពាន ធារាសាស្ត្រ ការដឹកជញ្ជូន និងទូរគមនាគមន៍ និងក្នុងការជំរុញស្តង់ដារពលកម្មអន្តរជាតិ នៅក្នុងឧស្សាហកម្មកាត់ដេរ ការជំរុញវិស័យទេសចរណ៍ និងការពង្រឹងបរិយាកាសវិនិយោគសម្រាប់ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិនិយោគ ។ ទោះបីនៅកម្ពុជា វិស័យធនាគារមានទំហំតូចក្តី ប៉ុន្តែបានរីកចម្រើនគួរឱ្យកត់សម្គាល់ និងទទួលរងផលប៉ះពាល់មិនសូវខ្លាំងទេពីវិបត្តិហិរញ្ញវត្ថុពិភពលោក ។ វិស័យនេះមានការគ្រប់គ្រងយ៉ាងហ្មត់ចត់ពីធនាគារជាតិនៃកម្ពុជា និងទទួលបានការជឿទុកចិត្តពីសំណាក់រដ្ឋាភិបាល វិស័យឯកជន និងប្រជាជនគ្រប់ស្រទាប់ ។

កន្លងមក កម្ពុជាអាចប្រើប្រាស់ចំណុចខ្លាំងរបស់ខ្លួនបាន ។ រាជរដ្ឋាភិបាលនៅតែប្តេជ្ញាធ្វើការគ្រប់គ្រង និងទាញយកផលពីធនធានធម្មជាតិដ៏សម្បូរបែបរបស់ប្រទេស ប្រកបដោយទំនួលខុសត្រូវខ្ពស់ ដើម្បីបានផលចំណេញជាអតិបរមាដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ការបង្កើនចំណូលជូនប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ និងដើម្បីដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងអភិបាលកិច្ច ការគ្រប់គ្រង ការដោះស្រាយទំនាស់ ទំនួលខុសត្រូវរបស់ក្រុមហ៊ុន និងការគ្រប់គ្រងបរិស្ថាន ។ រដ្ឋាភិបាលក៏ប្តេជ្ញាបន្តអនុវត្តវិធីសាស្ត្រមានតុល្យភាពល្អ សំដៅជំរុញការប្រើប្រាស់ដីប្រកបដោយផលិតភាព ជាពិសេសការប្រើប្រាស់ដីនៅតាមតំបន់ជនបទ សម្រាប់ការអភិវឌ្ឍកសិកម្ម និងជនបទ និងការកាត់បន្ថយភាពក្រីក្រ ។ រដ្ឋាភិបាលក៏បង្ហាញពីជំហរព្យាយាមឆ្លើយតបតាមតម្រូវការរបស់វិស័យឯកជន ហើយរឿងនេះសំខាន់ខ្លាំងណាស់សំរាប់វិស័យត្រូវអភិវឌ្ឍន៍ជាអាទិភាព ដូចជា ពិពិធកម្មសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ថាមពល ទូរគមនាគមន៍ និងសេវាកម្មហិរញ្ញវត្ថុ ។ តាមរយៈគំនិតផ្តួចផ្តើមផ្សេងៗ ដូចជា វេទិការដ្ឋាភិបាលជាមួយវិស័យឯកជន គោលនយោបាយចំហជើងមេឃ និងគោលនយោបាយវិនិយោគ ជាដើម រដ្ឋាភិបាលបានជួយគាំទ្រ និងលើកស្ទួយសមត្ថភាពរបស់វិស័យឯកជនឱ្យរីកលូតលាស់ និងអាចប្រកួតប្រជែងនៅទីផ្សារក្នុងតំបន់ និងពិភពលោក ។

## វិបត្តិសាកលៈ ផលប៉ះពាល់ និងការឆ្លើយតប

ដោយសារតែស្ថានភាពមិនអំណោយផលផុសចេញពីវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងឆ្នាំ២០០៨ មានប្រមាណ ៧% ប៉ុណ្ណោះ ធៀបនឹងកំណើនជាមធ្យមជាង ១០% ក្នុងមួយឆ្នាំ ក្នុងរយៈពេលបួនឆ្នាំបន្តបន្ទាប់មុននេះ ហើយតាមការព្យាករណ៍ កំណើនក្នុងឆ្នាំ២០០៩ នឹងបន្តធ្លាក់ចុះទៀត ។ ក្នុងស្ថានភាពដ៏លំបាកនេះ រដ្ឋាភិបាលបានចាត់វិធានការណ៍ជាប្រព័ន្ធ និងជាខ្សែសង្វាក់ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ ព្រមទាំងជំរុញកំណើនតាមរយៈវិធានការសារពើពន្ធ និងការជួយសម្រួលពាណិជ្ជកម្ម និងវិនិយោគ ។ រដ្ឋាភិបាលក៏ផ្តោតផងដែរលើការពង្រឹងបន្ថែមនូវប្រព័ន្ធសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋ ។

ទោះបីរដ្ឋាភិបាល បានដាក់អនុវត្តវិធានការមួយចំនួនដើម្បីដោះស្រាយឥទ្ធិពលវាក៏ដោយ ក៏វិបត្តិនៅតែកើតមានជាបន្តទៀតដែរ ។ វិបត្តិនេះមានផលប៉ះពាល់ទៅលើវិស័យសេដ្ឋកិច្ចសំខាន់ៗ ធ្វើឱ្យអត្រាកំណើនខាងកាត់ដេរ ទេសចរណ៍ និងសំណង់ ជាដើម ធ្លាក់ចុះអស់ ១៥-២០% ហើយជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចទាំងមូល និងប្រជាជនកម្ពុជា ។ ប្រការនេះមានន័យថា គ្រប់ៗគ្នាត្រូវប្រឹងប្រែងច្រើនថែមទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមធំៗមួយចំនួន (ប្រអប់ ១) ។

វិធានការឆ្លើយតបនឹងវិបត្តិនេះ ត្រូវរៀបចំឱ្យបានសក្តិសិទ្ធិ ដើម្បីជួយការពារ និងគាំទ្រដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ជាពិសេសអ្នកដែលបានបាត់បង់ការងារដោយសារការធ្លាក់ចុះនៃវិស័យនាំចេញ (ដូចជា កាត់ដេរ កម្មន្តសាល សំណង់ ទេសចរណ៍) ពលករធ្វើចំណាកស្រុកទៅប្រទេសជិតខាងដែលត្រូវចូលមកកម្ពុជាវិញ គ្រួសារក្រីក្រនៅទីជនបទដែលបានថយចុះប្រាក់ចំណូល និងកើនបន្ទុកចំណាយដោយសារមានសមាជិកគ្រួសារវិលត្រលប់មកពីទីក្រុងព្រោះមិនមានការងារធ្វើ សហគ្រាសខ្នាតតូចនិងមីក្រូ ជាអ្នកផ្តល់សេវានៅទីប្រជុំជនជួយទ្រទ្រង់ដល់ឧស្សាហកម្មនានាដែលត្រូវប៉ះពាល់ជាអវិជ្ជមានដោយសារវិបត្តិ ប្រជាជនក្រីក្រស្រាប់ដែលជាអ្នកមានការងារធ្វើ ឬមានការងារធ្វើមិនពេញលេញ និងដែលបានបាត់បង់ឱកាសល្អដោយសារសកម្មភាពសេដ្ឋកិច្ចរួមចុះ ព្រមទាំងពួកយុវជនដែលឈានចូលមកក្នុងទីផ្សារការងារចំពេលសេដ្ឋកិច្ចរួមចុះ និងមានឱកាស

---

* អត្ថបទនេះ ជាសេចក្តីសង្ខេបសុន្ទរកថាគន្លឹះបើកសន្និសីទ ថ្លែងដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ការងារតិចតួច ។ ចំពោះក្រុមជនងាយរងគ្រោះទាំងអស់នេះ យើងមានកាតព្វកិច្ចធ្វើយ៉ាងណា ឱ្យការឆ្លើយតបរបស់យើងចំពោះវិបត្តិ មានភាពសមស្របតាមតម្រូវការរបស់ពួកគេ ។

បញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានមិនត្រឹមតែកិច្ចសហប្រតិបត្តិការដ៏សក្តិសិទ្ធិ និងសកម្មរវាងរដ្ឋាភិបាល គ្រប់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការសម្របសម្រួល និងកិច្ចសហការដ៏សក្តិសិទ្ធិនៅក្នុង និងរវាងក្រសួងមន្ទីររបស់រដ្ឋាភិបាល និងសហគមន៍អ្នកអភិវឌ្ឍន៍ទៀតផង ។ ក្នុងវិស័យសំខាន់ៗ ដូចជា កសិកម្ម និងអភិវឌ្ឍន៍ជនបទ ជាដើម ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការស្រោចស្រពនិងគ្រប់គ្រងធនធានទឹក ការជួយសម្រួលពាណិជ្ជកម្ម ការប្រស្រ័យទាក់ទង និងសហប្រតិបត្តិការកាន់តែប្រសើររវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេស ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នានា ទាំងអស់នេះគឺចាំបាច់បំផុត ដើម្បីធានាថា កម្មវិធីអភិវឌ្ឍន៍នានារចនារៀបចំបានល្អ អនុវត្តបានលឿននិងមានប្រសិទ្ធភាព ហើយធនធានសំរាប់ជួយទ្រទ្រង់របស់ដៃគូអភិវឌ្ឍន៍នានា ត្រូវបានបើកផ្តល់ជាក់ស្តែង និងឆាប់រហ័ស ។ ការងារទាំងនេះ មិនមែនងាយស្រួលទេ ប៉ុន្តែលក្ខណៈធ្ងន់ធ្ងរនៃវិបត្តិតម្រូវឱ្យយើងធ្វើការរួមគ្នាទាំងអស់គ្នា ។

គេតែងនិយាយថា "វិបត្តិតែងតែដើរទន្ទឹមគ្នានឹងឱកាសល្អ" ។ វិបត្តិហិរញ្ញវត្ថុសាកលនាពេលបច្ចុប្បន្ន បានផ្តល់ឱកាសល្អសម្រាប់ឱ្យកម្ពុជា ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់ ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីការពង្រីកទីផ្សារតំបន់ ក៏ដូចជា ការពង្រីកពាណិជ្ជកម្ម និងវិនិយោគក្នុងតំបន់ ដែលជាកត្តាសំខាន់សម្រាប់ជួយកាត់បន្ថយការពឹងផ្អែកខ្លាំងពេក ទៅលើទីផ្សារខាងក្រៅ និងសម្រាប់បង្កើនសមត្ថភាពប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគពីខាងក្រៅតំបន់ថែមទៀត ។

កម្ពុជា ត្រូវធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយ ប្រទេសជិតខាងក្នុងមហាអនុតំបន់មេគង្គ សមាជិកអាស៊ាន និងដៃគូនានានៅក្នុងតំបន់ ដូចជា ចិន កូរ៉េខាងត្បូង និងជប៉ុន ដើម្បីស្វែងរកដំណោះស្រាយ និងយុទ្ធសាស្ត្រក្នុងតំបន់សំរាប់ជួយទប់ទល់នឹងវិបត្តិ និងធ្វើឱ្យតំបន់មានភាពរឹងមាំ អាចធន់ទ្រាំបានល្អនឹងវិបត្តិផ្សេងៗនាពេលអនាគត ។ កម្ពុជា ត្រូវធ្វើការរួមគ្នាជាមួយសមាជិកអាស៊ានឯទៀតៗ ដើម្បីលើកកម្ពស់ពាណិជ្ជកម្មសេរីក្នុងតំបន់ បណ្តាញផលិតកម្ម និងចំណាយប្រើប្រាស់ ដើម្បីបង្កើតយុទ្ធសាស្ត្រជាក់លាក់សំដៅញ៉ាំងឱ្យការប្តេជ្ញាចិត្តផ្សេងៗនៅក្នុងធម្មនុញ្ញអាស៊ាន អនុវត្តបានសំរេច ដើម្បីកាត់បន្ថយគម្លាតកំរិតអភិវឌ្ឍន៍នៅក្នុងអាស៊ាន និងដើម្បីអនុវត្តគំនិតផ្តួចផ្តើមឈៀងម៉ៃ សំដៅពង្រឹងយន្តការ និងស្ថាប័នហិរញ្ញវត្ថុក្នុងតំបន់សំរាប់ជួយគាំទ្រដល់កំណើន និងការអភិវឌ្ឍន៍ និងការពារបណ្តាប្រទេសអាស៊ីខាងកើតទប់ទល់នឹងការប៉ះទង្គិចផ្សេងៗពីខាងក្រៅនាពេលអនាគត ។

ក្នុងបរិការណ៍សេដ្ឋកិច្ចសាកល កម្ពុជាគាំទ្រចំពោះប្រទេសកំពុងអភិវឌ្ឍន៍ធំៗគឺ ចិន ឥណ្ឌា និងឥណ្ឌូនេស៊ី ដែលអាចនិយាយក្នុងនាមប្រទេសកំពុងអភិវឌ្ឍន៍ឯទៀតៗ ដើម្បីធានាឱ្យមានការកសាងយុទ្ធសាស្ត្រដ៏សក្តិសិទ្ធិក្នុងតំបន់ និងពិភពលោក សំរាប់ឆ្លើយតបនឹងវិបត្តិ ធានាឱ្យមានការប្តេជ្ញាចិត្តកាន់តែមុតមាំលើការកាត់បន្ថយគម្លាតកំរិតអភិវឌ្ឍន៍ លើការអនុវត្តការប្តេជ្ញាចិត្តផ្តល់ជំនួយអភិវឌ្ឍន៍របស់ប្រទេសអភិវឌ្ឍន៍ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការបើកផ្តល់ថវិកាទាន់ពេលវេលា និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍នានា និងលើការជឿនលឿនទៅមុខឥតឈប់នៃកំណែទម្រង់ជាបន្ទាន់នូវស្ថាប័នហិរញ្ញវត្ថុសំខាន់ៗ ដើម្បីឱ្យស្ថាប័នទាំងនោះដំណើរការកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបតាមតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

បញ្ហាសំខាន់ៗផ្សេងទៀតដែលផុសចេញពីបទពិសោធន៍របស់កម្ពុជាក្នុងការទប់ទល់នឹងវិបត្តិ ក៏គួរយកមកពិចារណាយ៉ាងល្អិតល្អន់ដែរ ដូចជា ១-តើកម្ពុជា និងប្រទេសក្នុងតំបន់ អាចតាមដានយ៉ាងណាពីផលប៉ះពាល់នៃវិបត្តិ ដើម្បីបង្កើតយុទ្ធសាស្ត្រឆ្លើយតប ជាពិសេសសម្រាប់ជួយជនក្រីក្រ និងជនងាយទទួលរងគ្រោះ ២-តើរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នអប់រំ អាចធ្វើការជាមួយគ្នាបែបណា ដើម្បីឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា ជាពិសេស ការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់កសាងកម្លាំងពលកម្មជំនាញ ៣-តើមានយុទ្ធសាស្ត្រអ្វីខ្លះ សំរាប់ឱ្យកម្ពុជាគ្រប់គ្រងបានល្អបំផុតលើដំណើរការឆ្លងកាត់វិបត្តិ និងការពារពង្រឹងវិស័យគន្លឹះៗដែលជំរុញកំណើន និងការអភិវឌ្ឍនៅកម្ពុជា គឺមានកសិកម្ម ការអភិវឌ្ឍជនបទ ទេសចរណ៍ កម្មន្តសាលកម្ម អចលនទ្រព្យ និងសំណង់ ៤-តើមានគោលនយោបាយ និងសកម្មភាពជាអាទិភាពអ្វីខ្លះ ដែលគួរដាក់ចូលក្នុងផែនការអភិវឌ្ឍន៍របស់កម្ពុជា ដើម្បីឆ្លើយតបនឹងវិបត្តិ និងដែលជួយជំរុញកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នស្រាវជ្រាវខាងគោលនយោបាយ ៥-តើស្ថាប័នកម្រិតតំបន់ និងពិភពលោក ដូចជា ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍ពហុភាគីជាដើម អាចធ្វើអ្វីខ្លះ ដើម្បីជួយបំពេញតម្រូវការ របស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការទប់ទល់នឹងវិបត្តិបច្ចុប្បន្ន និងបង្ការវិបត្តិនាពេលអនាគត?

ការងារត្រូវធ្វើនៅមានច្រើនណាស់ ហើយជោគជ័យភាគច្រើនពឹងផ្អែកលើការប្តេជ្ញាចិត្ត និងកិច្ចសហការរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នស្រាវជ្រាវខាងគោលនយោបាយនានា ដែលត្រូវធ្វើការរួមគ្នា ដើម្បីបម្រើផលប្រយោជន៍របស់ប្រទេសកម្ពុជា ៕

**ប្រអប់ ១: បញ្ហាប្រឈមសំខាន់ៗផុសចេញពីវិបត្តិ**

**បញ្ហាប្រឈម ១:** ធ្វើពិពិធភាវូបនីយកម្មទីផ្សារសម្រាប់ផលិតផលកាត់ដេរ និងទំនិញកម្មន្តសាលផ្សេងទៀត ដោយចូលទៅទីផ្សារ អាស៊ីបូព៌ា មជ្ឈិមបូព៌ា អាហ្វ្រិក និងទីផ្សារខុសប្លែកពីមុនផ្សេងៗ ។

**បញ្ហាប្រឈម ២:** កែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យទេសចរណ៍ និងអភិវឌ្ឍតំបន់ទេសចរណ៍ថ្មីៗបន្ថែមទៀត និងយកចិត្តទុកដាក់រៀបចំកញ្ចប់ទេសចរណ៍ឱ្យកាន់តែមានភាពទាក់ទាញ ។

**បញ្ហាប្រឈម ៣:** ពង្រីក និងធ្វើពិពិធកម្មវិស័យកសិកម្ម, ទាក់ទាញវិនិយោគប្រកបដោយគុណភាពក្នុងវិស័យកសិអាជីវកម្ម និងកែលំអតំណភ្ជាប់ផ្សេងៗក្នុងពាណិជ្ជខាងកសិកម្ម កំណែទម្រង់ដីធ្លី និងការកែច្នៃកសិផល ។

**បញ្ហាប្រឈម ៤:** បង្កើនវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសការផលិតថាមពល ដើម្បីកាត់បន្ថយថ្លៃដើមថាមពល ។

**បញ្ហាប្រឈម ៥:** ជំរុញខ្លាំងក្លា និងជួយទ្រទ្រង់ដល់ការបង្កើតទ្រព្យធន និងការកែលំអជីវភាពរស់នៅរបស់ប្រជាជន ដោយអនុលោមតាមគោលការណ៍ និងនីតិវិធីទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ។

**បញ្ហាប្រឈម ៦:** ជួយដល់ជនក្រីក្រ និងជនងាយរងគ្រោះ ដែលប្រឈមមុខនឹងវិបត្តិតាមរយៈការពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គម ដោយអនុវត្តវិធានការ ដូចជាការផ្តល់ជំនួយស្បៀងសង្គ្រោះបន្ទាន់និងការឧបត្ថម្ភសង្គមកិច្ចជាទឹកប្រាក់ជាដើម ។

**បញ្ហាប្រឈម ៧:** ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងតំបន់ និងបណ្តាប្រទេសមិនសូវអភិវឌ្ឍ ដើម្បីលើកកំពស់ផលប្រយោជន៍រួមនៅក្នុងឆាកអន្តរជាតិ ។